## តើខ្ញុំអាចប្ដូរឬដកលិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្តរបស់ខ្ញុំបានឬទេ?

ដរាបណាអ្នកនៅមានលទ្ធភាព អ្នកនៅតែអាចប្ដូរឬដកលិខិតណែនាំ ជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តរបស់អ្នកនៅពេលណាក៏បាន។ បើអ្នក បានបាត់បង់អ្នកមានលទ្ធភាព អ្នកគ្រាន់តែអាចប្ដូរឬដកហូតលិខិតណែនាំ របស់អ្នកប៉ុណ្ណោះ បើសិនជាបានសរសេរបញ្ចូលរួចហើយ។ ការប្ដូរនានាគឺត្រូវបានធ្វើឡើងជាលាយល័ក្ខអក្សរ។ ចូរឲ្យប្រាកដ និយាយប្រាប់ម្នាក់ៗដែលមានក្រដាសសំណៅចម្លង បើសិនជាអ្នកបានលុបចោលលិខិតណែនាំជាផ្លូវការជាមុនរបស់អ្នក។

## តើយ៉ាងណា បើសិនជាខ្ញុំមានលិខិតណែនាំទៅគ្រូពេទ្យ ឬ លិខិតប្រគល់សិទ្ធិមេធាវីរួចហើយ?

បើសិនជាមានការផ្ទុយគ្នារវាងលិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្ត ហើយនិង-លិខិតណែនាំផ្សេងៗ ដូចជាលិខិតណែនាំ ទៅគ្រូពេទ្យ នោះលិខិតណែនាំដែលថ្មីជាងគេបំផុតនឹងត្រូវជាលិខិតដែល មានសុពលភាពស្របច្បាប់។ ដើម្បីបន្ថយភាពច្រឡំមិនដាច់ស្រេចល្អគឺ ប្រហែលត្រូវមានមនុស្សម្នាក់ដើរតួជាភ្នាក់ងារនៃលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តរបស់អ្នក និងមានអំណាចតំណាងជាមេធាវី។

## តើខ្ញុំអាចរកឃើញពត មានច្រើនថែមទៀតអំ ពីលិខិតណែនាំជាផ្លូវការ ជាមុននៃសុខភាពផ្លូវចិត្តនៅទីណា?

- ដើម្បីបង្កើតលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្ត ចូរទៅ: www.dshs.wa.gov/dbhr/advdirectives.shtml.
- អានច្បាប់ ក្រមកែប្រែនៃរដ្ឋវ៉ាស៊ីនតោន (RCW) 71.32 តាមបណ្ដាញអិនធឺណិតនៅ http://www.leg.wa.gov.
- ចូរទូរស័ព្ទទៅគ្រូពេទ្យផ្ដល់ការព្យាបាលសុខភាពផ្លូវចិត្ត ឬផ្នែកសេវាអ្នកទទួលបណ្ដឹងពីពលរដ្ឋ។
- ចូរទូរស័ព្ទទៅការិយាល័យនាយកដ្ឋានសុខភាពនិងការស្ដារចរិយា (DBHR) នៃភាពជាដៃគូរបស់អ្នកប្រើប្រាស់ តាមលេខ 1-800-446-0259 លេខបន្ត 7 ។

សុខភាពផ្លូវចិត្ត

# លិខិតណែនាំ ជាផ្លូវការជាមុន



ពតមានសំរា
ប់អ្នកប្រើប្រាស់

Washington State
Department of Social
& Health Services

DSHS 22-641 CA (Rev. 12/12)

## អ្វីហៅថា លិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្ត?

លិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្ត (ៈ។ឌ) គឺឯកសារជា លាយលក្ខអក្សរ ដែលអធិប្បាយពីការណែនាំនិងការចូលចិត្តសំរាប់ការ ព្យាបាលនិងការមើលថែ នៅពេលដែលអ្នកមានការពិបាកក្នុងទំនាក់ទំនង និងការធ្វើសេចក្តីសំរេច។ គឺអាចផ្តល់ពត មានទៅអ្នកដទៃអំពី អ្វីដែលត្រូវព្យាបាលដែលអ្នកចង់បានឬមិនចង់បាន ហើយនិងអាចសំគាល់ ជនម្នាក់ដែលហៅថា"ភ្នាក់ងារ" ដែលអ្នកទុកចិត្ត ដើម្បីធ្វើការសំរេចចិត្ត និងសំរេចសេចក្តីជំនួសអ្នក។

## តើអ្នកគួរមានលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តឬទេ?

គឺមានប្រយោជន៍ជាច្រើន ក្នុងការមានលិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្ត:

- អ្នកនឹងមានការគ្រប់គ្រងយ៉ាងច្រើនលើអ្វីដែលនឹងកើតឡើងចំពោះអ្នក នៅពេលដែលមានវិបត្តិ។
- អ្នកដែលផ្តល់ការព្យាបាលនិងអ្នកដទៃទៀតនឹងដឹងនូវអ្វីដែលអ្នកចង់បាន ទោះបីជាអ្នកមិនអាចនិយាយដោយខ្លួនអ្នកបានក៏ដោយ។
- លិខិតណែនាំរបស់អ្នកអាចជួយនាយកគ្រប់គ្រងសំណុំរឿងរបស់អ្នក និងអ្នកដទៃទៀត ដែលបានចូលរួមក្នុងការព្យាបាលសុខភាពផ្លូវចិត្តរបស់អ្នក។
- ច្បាប់តំរូវឲ្យអ្នកផ្តល់ការព្យាបាលទាំងអស់ដើម្បីគោរពនូវអ្វីដែលអ្នកបាន សរសេរនៅក្នុងលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តឲ្យបាន ច្រើនបំផុតដែលអាចធ្វើទៅបាន។

## តើមានអ្វីនៅក្នុងលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្ត?

អ្វីៗដែលអាចចូលរួមនៅក្នុងការព្យាបាលរបស់អ្នក អាចត្រូវជាចំណែកនៃ លិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្ត។ ឧទាហរណ៍:

- ព្រមព្រៀងឬបដិសេធ ជាពិសេសថ្នាំពេទ្យឬការឲ្យចុះឈ្មោះសំរាក ក្នុងមន្ទីរពេទ្យ;
- អ្នកណាខ្លះអាចមកសួរសុខទុក្ខអ្នក បើសិនអ្នកសំរាកក្នុងមន្ទីរពេទ្យ;
- តើអ្នកណាដែលអ្នកចាត់តាំងដើម្បីធ្វើការសំរេច និងធ្វើអ្វីៗជំនួសអ្នក (ភ្នាក់ងាររបស់អ្នក);
- អ្វីៗផ្សេងទៀតដែលអ្នកចង់ឬមិនចង់ក្នុងការមើលថែនៅពេលអនាគត។

## តើខ្ញុំគួរមានភ្នាក់ងារឬទេ?

អ្នកមានជំរើសក្នុងការរកភ្នាក់ងារម្នាក់:

- ដែលមានអាយុយ៉ាងតិច 18 ឆ្នាំ។
- ដែលស ាល់អ្នក និងដឹងអ្វីដែលអ្នកចង់នៅពេលដែលអ្នកនៅមានសុខភាពល្អ។
- អ្នកអាចប្រាប់ពីការព្យាបាលទៅគ្រូពេទ្យអំពីចំណូលចិត្តរបស់អ្នក និងអាចផ្តល់យោបល់សំរាប់អ្នក។

តាមច្បាប់ ទីភ្នាក់ងាររបស់អ្នកមិនអាចជាវេជ្ជបណ្ឌិតរបស់អ្នកទេ, នាយក គ្រប់គ្រងសំណុំរឿងរបស់អ្នក ឬអ្នកផ្តល់ការបំរើគេហជនរបស់អ្នកនោះទេ លើកលែងតែជននោះគឺក៏ជាប្តីឬប្រពន្ធ, កូនពេញវ័យ, ឬបងឬប្អូនបង្កើត របស់អ្នក។

## តើជនណាគួរទទួលសំណោចម្លងនៃលិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្តរបស់ខ្ញុំ?

បើអ្នករកភ្នាក់ងារ ជននោះត្រូវតែផ្តល់លិខិតចម្លងឲ្យ។ ក្រោយមកទៀត គឺស្រេចតែលើរូបអ្នក ដែលអ្នកត្រូវផ្តល់លិខិតចម្លងឲ្យទៅពួកគេ។ គិតអំពីការផ្តល់លិខិតមួយទៅអ្នកផ្តល់ ការព្យាបាលផ្នែកសុខភាពផ្លូវចិត្តពេល បច្ចុប្បន្នរបស់អ្នក, មេធាវីរបស់អ្នក (បើសិនអ្នកមានម្នាក់) និងសមាជិកគ្រួសារណាដែលអ្នកទុកចិត្ត។ នាំយកសំណោចម្លងមួយ សម្រាប់ បើសិនជាអ្នកត្រូវបានគេចុះឈ្មោះឲ្យសំរាកក្នុងមន្ទីរពេទ្យសំរាប់ សុខភាពផ្លូវចិត្ត។ គ្រូពេទ្យណាម្នាក់ដែលទទួលការព្យាបាលដែលទទួល លិខិតចម្លង គឺតំរូវឲ្យធ្វើការព្យាបាលវាជាចំណែកនៃឯកសារផ្នែកពេទ្យ។

## តើខ្ញុំបង្កើតលិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តរបៀបយ៉ាងណា?

អ្នកអាចរកឃើញក្រដាសលិខិតនេះនៅ:

www.dshs.wa.gov/mentalhealth



## តើអ្វីៗទាំងអស់នឹងអនុញ្ញាតឲ្យដាក់ចូលនៅក្នុងលិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្តឬទេ?

នេះគឺជាឧទាហរណ៍ដែលរឿងនោះមិនត្រូវអនុញ្ញាតឲ្យដាក់ចូលក្នុង លិខិតណែនាំជាផ្លូវការជាមុននៃសុខភាពផ្លូវចិត្តរបស់អ្នកទេ:

- ការណែនាំរបស់អ្នកមានកំរិតផ្ទុយពីបទដ្ឋានផ្នែកពេទ្យ ឬមិនអាចមាន។
- ការណែនាំរបស់អ្នកដូចខាងក្រោមនេះអាចបំពានលើច្បាប់របស់រដ្ឋឬ សហព័ន្ធ។
- អ្នកបានដាក់ឱ្យសំរាកក្នុងមន្ទីរពេទ្យនៅក្រោមអំពើដែលមិនស្ម័គ្រចិត្ត ឬជាប់ពន្ធនាគារ។

## តើខ្ញុំអាចធ្វើអ្វីបានខ្លះ បើខ្ញុំមានអារម្មណ៍ថា លិខិតណែនាំជាផ្លូវការជាមុន នៃសុខភាពផ្លូវចិត្តមិនបានត្រូវគេធ្វើតាម?

បើសិនជាអ្នកមានអារម្មណ៍ថា សុខភាពផ្លូវចិត្ត ឬលិខិតណែនាំជាផ្លូវការ ជាមុននៃសុខភាពផ្លូវចិត្តរបស់អ្នកមិនបានត្រូវគេធ្វើតាម អ្នកអាចទទួល ពត មាន ឬដាក់បណ្តឹងតួញត្អែរជាមួយនឹងក្រសួងសុខភាពរបស់ រដ្ឋវ៉ាស៊ីនតោន (DOH) :

- អ្នកអាចទូរស័ព្ទទៅក្រសួង DOH តាមលេខ1-360-236-2620;
- អ្នកអាចអ៊ីមែលទៅក្រសួង DOH តាមអាស័យដ្ឋាន HSQAComplaintINtake@doh.wa.gov; ឬ
- អ្នកអាចចូលទៅបណ្តាញអ៊ិនថឺណិតក្រសួង DOH តាមអាស័យដ្ឋាន www.doh.wa.gov

គ្រប់ការតួញត្អែរទាំងអស់គឺត្រូវបានពិនិត្យដោយក្រសួង DOH ឡើងវិញដើម្បីធ្វើការសំរេច បើសិនជាមានការបំពានលើច្បាប់ ឬបើក្រសួង DOH មានអំណាចដើម្បីដំណើរការតាមផ្លូវច្បាប់។ បើសិនជាមាន ការរំលោភលើច្បាប់និងអាជ្ញាធរដើម្បីដំណើរការអនុវត្តន៍តាមច្បាប់ នៃក្រសួង ឌឱះ ដើម្បីដឹកនាំការស៊ើបអង្កេត។